# លាងអារក្សនៅភូមិសំបូរ

**លាងអារក្ស** គឺជាឈ្មោះមួយដែលមហាជនជាទូទៅស្គាល់ តែម្តងម្កាលអ្នកភូមិសំបូរ (ខេត្តកំពង់ធំ) ហៅកិច្ចនេះថា "**ឡើងពាង**" ឬ "**ដាក់របៀង**" ហើយជួនគេទៀតហៅថា "**ដាក់របៀងឡើងពាង**" តែម្តង។ កិច្ចពិធីនេះធ្វើឡើងដើម្បីដឹងគុណដល់អារក្សដែលបានថែរក្សាភូមិស្រុកឱ្យជៀសផុតពីជំងឺដង្កាត់ផ្សេងៗ គ្រោះធម្មជាតិ និងសូមឱ្យមានភ្លៀងគ្រប់គ្រាន់សម្រាប់ស្រោចស្រពផលដំណាំ។ ដ្បិត អារក្ស គឺសំដៅលើអមនុស្សដែលមានចិត្តល្អ តែងតែជួយកូនសិស្សគុណរបស់ខ្លួន។ តើលាងអារក្ស ឬដាក់របៀងឡើងពាងនៅភូមិសំបូរ (សំបូរព្រៃគុក) មានលំដាប់លំដោយ និងអត្ថន័យយ៉ាងណាខ្លះ?

ជាទូទៅអ្នកភូមិសំបូរតែងតែប្រារព្ធពិធីលាងអារក្សជារៀងរាល់ឆ្នាំ តែក៏មានផ្ទះខ្លះ២ឆ្នាំធ្វើម្តងដែរ ហើយពិធីនេះច្រើនប្រារព្ធឡើងតែពេលយប់ (ចាប់ពីម៉ោង ៥ ល្ងាចរហូតទល់ម៉ោង ៦ ព្រឹក)។ នៅក្នុងភូមិនេះ យ៉ាងហោចណាស់ក្នុងមួយឆ្នាំ មានគ្រួសារដែលលាងអារក្សប្រមាណជា ៦ គ្រួសារដែលមានលទ្ធភាពអាចប្រារព្ធកិច្ចនេះបាន។ រីឯគ្រួណាដែលមានសិស្សគណ[១]តិច គឺគ្មានលទ្ធភាពប្រារព្ធកិច្ចលាងអារក្សនោះទេ ហើយគេតែងប្តូរធ្វើកិច្ចដោយដោតជមជំនួសវិញដូចធ្លាប់ពន្យល់នៅក្នុងអត្ថបទមុន។ ការលាងអារក្សម្តងៗត្រូវចំណាយលើគ្រឿងរណ្តាប់ ពិសេសថ្លៃភ្លេងច្រើន ពោល គឺប្រមាណជា ៥៥០,០០០ រៀល ម្ល៉ោះហើយទើបបានជារូបស្នងខ្លះឥតមានលទ្ធភាព ព្រោះខ្លួនមានសិស្សគណតិចតួច។ កិច្ចលាងអក្សនេះធ្វើមិនដូចគ្នានោះទេ ពីគ្រួមួយទៅគ្រួមួយទៀត គ្រួខ្លះមានដាល់ គ្រួខ្លះមិនមាន គ្រួខ្លះមានកិច្ចម្តាយដើម គ្រួខ្លះទៀតមិនមាន ហើយនៅមានកិច្ចច្រើនទៀតដែលខុសគ្នា ដែលមិនអាចរៀបរាប់បានទាំងអស់នោះទេ។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងលើកយកតែកិច្ចលាងអារក្សនៅផ្ទះតាលូន (រូបស្នងអារក្សម្នាក់) មួយប៉ុណ្ណោះដែលមានលំដាប់លំដោយដូចខាងក្រោម។

---

[១] សិស្សគណ សំដៅដល់មនុស្សមួយក្រុមដែលអារក្សធ្លាប់ជួយថែរក្សា ឬជួយសម្រេចបំណង់អ្វីមួយបន្ទាប់ពីគេបានទៅពឹងពរ។ លុះបានសម្រេចហើយ អ្នកនោះនឹងក្លាយជាសិស្សគណរបស់អារក្ស ហើយកូនៗរបស់គេក៏រាប់ជាខ្សែនៃអារក្សដែរ ពោល គឺខ្សែខាងម្តាយ ឬខាងឪពុក។

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

បន្ទាប់ពីរកថ្ងៃប្រារព្ធកិច្ចលាងអារក្សបានហើយ រូបស្នងបានដើរប្រាប់ពីដំណឹងនៃការលាងនេះ និងប្រាប់រូបស្នងដទៃទៀតឲ្យមកចូលរួមពិធីជាមួយគ្នា ហើយយើងសង្កេតឃើញថាដំណើរទៅជួបរបស់រូបស្នង គឺតែងឃើញមានចេកមួយស្និត ធូប និងទឹកគ្រូចមួយដបទៅជាមួយ។ លុះដល់ថ្ងៃកំណត់វេលា ពេលថ្ងៃគ្រាន់តែរៀបចំរណ្តាប់មួយចំនួន ដូចជា ពៃដើងត្រុំនិងពៃជ្រួតពានទិស ច្រូម ស្លាធម៌ បាយសី ជាដើម។ មុនចាប់ផ្តើម គេយករណ្តាប់មួយចំនួនទៅថ្វាយអ្នកតាទ្វារនៅកណ្តាលភូមិជាមុនសិន។ បន្ទាប់មក គេយករណ្តាប់ទៅថ្វាយទួលប្រាសាទចាស់មួយនៅត្រង់សាលាបឋមសិក្សាសំបូរ ហើយចុងក្រោយគេយករណ្តាប់ថ្វាយលោកយាយនៅទួលប្រាសាទបុរាណ។ ការធ្វើបែបនេះក្នុងគោលបំណងជម្រាបអស់លោក សុំទឹកសុំដីដើម្បីឲ្យដំណើរការលាងអារក្សប្រព្រឹត្តទៅដោយជោគជ័យ។ កិច្ចបន្ទាប់មកទៀត យើងឃើញស្នំ និងកូនសិស្សគណមួយចំនួនទៅរកគ្រូអារក្ស សុំទម្លាក់តោកចុះមកដីដើម្បីរៀបចំកម្មវិធី (រូបលេខ២១)។ កិច្ចពិធីចាប់ផ្តើមដោយមានការសែនបាយចំនួន ៤ ចាន មីសួរ ៥ ចាន ចេក និងនំក្ងាកង្កែបមួយចាន។។ ការសែនត្រង់នេះ គឺអ្នកភូមិសែនប្រាប់ជីដូនជីតា ហើយក្រុមក្មេងជាអ្នកសែននៅទីនេះ (រូបលេខ២២)។ បន្ទាប់មកទៀត ស្គរផ្លាក៏ចាប់ផ្តើមបន្លឺ អារក្សក៏ចូល មានសិស្សម្នាក់ចូលទៅប្រដាល់ជាមួយអារក្ស។ ក្នុងន័យជាកិច្ច សិស្សនោះ តម្រូវឲ្យយកអ្វីដែលអារក្សកាន់នឹងដៃ ដូនកាលជាចេក ដូនជាស្រា បើដណ្តើមមិនបានទេសិស្សនោះតែងសំពះសុំ។ គេធ្វើបែបនេះ៣លើក ក្នុងមួយយប់ ពោលរវាងម៉ោង៧ម្តង ម៉ោង១ម្តង និងម៉ោង៥ទាបភ្លឺម្តងទៀត ហើយលេងម្តងៗ សិស្សដែលមកដាល់ជាមួយអារក្សត្រូវដណ្តើមយករបស់ពីដៃគ្រូអារក្សបីដងក្នុងមួយលើក (រូបលេខ២៣) ។

បើនិយាយអំពីក្មេងវិញឃើញមានស្គរផ្លាចំនួន២ និងផ្ទៃចបចំនួនមួយទុកសម្រាប់គោះ។ រូបស្នងចូលជាបន្តបន្ទាប់ និងឡកកញ្ចែងយ៉ាងសម្បើម តែយ៉ាងណាក៏មានពេលសម្រាកម្តងម្កាលដែរ ដ្បិតគ្រូចេញអស់ អត់មានអ្នករាំ ហើយក្មេងក៏សម្រាក។ ដូនជាគ្រូកំពុងរាំ អ្នកក្មេងអង្វរគ្រូថាចុះចាញ់គ្រូហើយ សូមគ្រូអនុគ្រោះ ដ្បិតគាត់វាយស្គរយូរចុកដៃពេក។ លុះដល់អាធ្រាត្រ គេយកពៃទៅចោលនៅខាងជើងផ្ទះលាងអារក្ស តែយ៉ាងណាមុនយកទៅចោលគេនាំគ្នាដើរប្រទក្សិណចំនួន ៣ ជុំ (រូបលេខ២៤)។ ក្នុងដំណើរនេះមានយាយម្នាក់កាន់កាំភ្លើងដើរពីក្រោយ (រូបលេខ២៥) ហើយមានអ្នកមួយចំនួនកាន់ទឹកបំពង់ ស្រាសមួយដប ចេកមួយស្និត។ បន្ទាប់ពីទុកដាក់រួចរាល់ហើយ គេនាំគ្នារត់មកវិញ ព្រោះថាយាយដែលកាន់កាំភ្លើងនោះដេញ។ យ៉ាងណាកិច្ចនេះមិន

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

ទាន់ចប់ត្រឹមប៉ុននេះទេ មានការចូលរូបផ្សេងៗ ដូចជា អ្នកស្រទុំស្តេចស្រឡាយ រំពាត់មាស តាជ័យ ពេជ្រវ័យ យាយគតាគ (ពេលចូលមិននិយាយអ្វីទាំងអស់) កង្ហារដែក (ចូលមករាំអង្គុយ ចេះតែអេះគូទ) ហើយនៅមានជាច្រើនទៀត ព្រោះរូបស្នងមួយអាចមានអារក្សចូលច្រើនលើសពីមួយ (រូបលេខ២៦)។ វាងម៉ោង៥ទៀបភ្លឺ មានកិច្ចមួយដែលអ្នកស្រុកហៅថា "***កិច្ចហៅព្រលឹង***" ដែលពេលនោះគេត្រូវការសិស្សរបស់អារក្ស ដើម្បីមកដណ្តើមទាបពីអារក្សៗ ក្រោយពីសិស្សដណ្តើមបានហើយ ស្រាប់តែរូបស្នងនោះដួលទៅក្រោយ ហើយមានមនុស្សពីរនាក់ទ្រជាប់ ហើយអ្នកទាំងពីរនោះត្រូវពើប មានន័យថាត្រូវស្រែកដាក់ត្រចៀកទាំងសងខាងរបស់រូបស្នងៗ បន្ទាប់ពើបរួចហើយ រូបស្នងនោះស្ទុះមកសង្រ្គប់តោក ហើយទើបអារក្សចេញ (រូបលេខ២៧)។ ក្រោយមកអ្នកភ្លេងលេងបទ "អក" ដើម្បីសាផ្កា (ស្ទឹកម្ទូ ស្ទឹកពោជយម ស្វា) សាផ្កាន (ក្រមាផ្នែកខាងលើ) សាជញ្ជាំង (ក្រម៉ាដែលនៅពីចំហៀង សាកម្រាល ដោយមានការច្រៀងបណ្តើរនិងសាបណ្តើរៗ ក្រោយសារួចតាៗពីរនាក់នោះសួរថា "***តើនរណាក្មេចក្រមានៅមាត់អណ្តូង?***" ពេលនោះមានយាយបន្ទរថា "***ជារបស់ខ្ញុំក្មេច***" តាពីរនាក់នោះបន្តថា "***កុហកទេដឹង?***" យាយៗបន្តថា "***ទេមែន***"ៗ តាពីរនាក់សួរបន្ថែមថា "***តើបានអ្វីមកបញ្ជាក់?***" យាយៗឆ្លើយថា "***ក្រមានឹងមាន១៩ហត្ថ***"ៗ តា២នាក់នោះក៏បានវាស់ដើម្បីបញ្ជាក់ថាមានប្រវែងប៉ុណ្ណឹងមែន ក៏បោះទៅក្រៅរោង កន្លែងដែលគ្មានមនុស្សៗ នេះបញ្ជាក់ថា សំឡេងយាយៗដែលឆ្លងឆ្លើយជាមួយគាត់គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ណាមួយពេលសន្ទនាគ្នា តាៗពីរនាក់នោះមិនបានមើលយាយៗនោះទេ ពោល គឺអាចនិយាយបានថា សំឡេងរបស់យាយៗនោះ ជាសំឡេងអមនុស្ស (រូបលេខ២៨)។ ចុងក្រោយមានមនុស្ស២នាក់មកសែងពាននិងពៃទៅចោល ហើយមានមនុស្សម្នាក់កាន់រំពាត់សម្រាប់ដេញវាយអ្នកដែលយកពៃទៅចោល ហើយមានពីរនាក់កាន់ពានទិស និងពីរនាក់ទៀតកាន់ពៃដើងត្រុំនិងពៃជ្រួតៗ កិច្ចនេះចប់ត្រឹមយកពៃទៅចោលនៅវេលាម៉ោង ៦ ទៀបភ្លឺ (រូបលេខ២៩)។

ជារួមមក កិច្ចលាងអារក្សនៅភូមិសំបូរ គឺមានលំដាប់នៃកិច្ចជាវប្បធម៌ដោយឡែកមួយដែលគេនៅតែបន្តប្រារព្ធធ្វើជារៀងរាល់ឆ្នាំៗ ទោះលំដាប់លំដោយនៃកិច្ចមានរបៀបវែងឆ្ងាយយ៉ាងណាក្តី ក៏គោលបំណងសំខាន់នៃកិច្ច គឺធ្វើឡើងដើម្បីដឹងគុណដល់អារក្សដែលបានថែរក្សាភូមិស្រុកឱ្យជៀសផុតពីជំងឺដង្កាត់ផ្សេងៗ និងផ្តល់នូវទឹកភ្លៀងគ្រប់គ្រាន់សម្រាប់អ្នកស្រុក៕

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

## ឯកសារយោង

**អាន រស្មី**, ២០១០. *កិច្ចលាងអារក្សនៅភូមិសំបូរ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី ១៩, ភ្នំពេញ។



រូបលេខ១៖ បញ្ជាន់រូប ដើម្បីសុំទម្លាក់តោកចុះដី



រូបលេខ២៖ សែនបើកផ្លូវ ជម្រាបអស់លោក

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៣៖ ការប្រដាល់រវាងគ្រូអារក្ស និងសិស្សគណ



រូបលេខ៤៖ ការហែប្រទក្សិណមុនបញ្ជូនពែយកទៅចោល

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ២៥៖ កាន់កាំភ្លើងក្នុងនាមអ្នកការពារ នៅពេលយកពែទៅចោល



រូបលេខ២៦៖ គ្រូអារក្សជាច្រើនចូលរូប និងឡកកញ្ចែង

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៧៖ កិច្ចហៅព្រលឹង



រូបលេខ៨៖ កិច្ចសាពិដាន

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៩៖ កិច្ចបញ្ជូនពែយកទៅចោល

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង